# ខ្លឹមសារជំនឿលើព្រះយេស៊ូវគ្រីស្ទ ក្នុង៦មេរៀន

## មេរៀនទី៤ ព្រះអង្គនៅតែស្រលាញ់មនុស្សលោក

**លំនាំដើម**

**មេរៀមទី១** ព្រះគម្ពីរបរិសុទ្ធគឺជាអ្វី ហើយមកពីណា? ព្រះអាទិក មានការទំនាក់ទំនងជាមួយមនុស្ស

**មេរៀនទី២**

**«ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។»** យ៉ូហាន ៣:១៦

**«ដ្បិតព្រះ» តើព្រះមានលេក្ខណៈសម្បត្តិអ្វីណាខ្លះ?**

**មេរៀនទី៣ ការអស្ចារ្យនៃសេចក្ដីស្រលាញ់**

**«ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង»**

ដើម្បីយល់អំពីសេចក្ដីស្រលាញ់របស់ព្រះអង្គ ជាការចាំបាច់ដែលយើងស្គាល់សាច់រឿងពីជីដូនជាតាដំបូងបំផុតរបស់មនុស្ស គឺលោកតាអ័ដាម និងលោកយាយអេវ៉ា។

ព្រះបង្កើតលោកទាំងពីរយ៉ាងបរិសុទ្ធ ហើយដាក់គាត់ឲ្យរស់នៅកន្លែងបរិសុទ្ធដែរ ប៉ុន្តែលោកទាំងពីរបានសម្រេចចិត្តបះបោប្រឆាំងនឹងព្រះអង្គ។ លទ្ធផល សេចក្ដីស្លាប់ ការរង

ទុក្ខវេទនាគ្រប់បែបយ៉ាងចាប់ផ្ដើមមានឡើង។ ដោយព្រោះបាបរបស់លោកទាំងពីរ មនុស្ស បានដាច់ចេញពីព្រះ។ យើងទាំងអស់គ្នា គ្រប់តំណ បានត្រាប់តាមលោកតានិងលោកយាយដើមនោះ ដូច្នេះយើងមានទោស មានអំពើបាបដូចគ្នា។

តើលោកអ្នកចាំទេ មេរៀនមុន ខ្ញុំបានសួរបងបងប្អូនថា បើសិនព្រះអាទិករដែលបរិសុទ្ធ និងយុត្តិធម៌ នៅតែស្រលាញ់មនុស្ស នោះគួរសមទេ? មិនគួរឡើយ! គឺតាមរយៈបាបរបស់មនុស្សយើងទេ ដែលផែនដីរបស់ព្រះបានខូច។

តែព្រោះគម្ពីរថា «**ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង**»

ព្រះអង្គមិនគួរស្រលាញ់យើងទេ! ហេតុនេះហើយដែលសេចក្ដីស្រលាញ់របស់ទ្រង់អស្ចារ្យ!

តើលោកអ្នកទាន់យល់ទេថា <u>ខ្លួនជាអ្នកមានបាប</u> <u>ជាអ្នកមានទោស</u>នៅចំពោះព្រះអាទិករឬ? គោលការណ៍នេះសំខានណាស់ ដើម្បីយល់ជំរៅនៃសេចក្ដីស្រលាញ់របស់ព្រះទៅកាន់យើង។

**«ដូច្នេះ ដូចដែលបាប បានចូលមកក្នុងពិភពលោក តាមរយៈមនុស្សម្នាក់ (លោកអ័ដាម) ហើយសេចក្ដីស្លាប់ចូលមកតាមរយៈបាបជាយ៉ាងណា នោះសេចក្ដីស្លាប់ក៏រាលដាលដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ <u>ដ្បិតគ្រប់គ្នាបានធ្វើបាប</u>»** រ៉ូម ៥:១២

អំពើបាបមានច្រើនយ៉ាង គឺការប្រព្រឹត្តខុស ដូចជាសហាយស្មន់ ការលួច ការបោកប្រាស់ អំពើពុករលួយ និយាយអាក្រក់ ការផឹកស្រវឹង ជក់គ្រឿងញៀន ចាប់រំលោភគេ សម្លាប់គេ រំលូតកូន ក្បត់ប្ដីប្រពន្ធ ភូតភរ ការរមិលគុណ ។ល។

បើយើងគិតអំពីបាបក្នុងចិត្តវិញ មាន ការលោភលន់ ច្រណែន ស្អប់ មើលងាយ អំនួតអួតអាង ខ្វះសេចក្តីមេត្តា កំហឹង ។ល។

**តែព្រោះគម្ពីរថា «ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង»**

តើអ្នកចាំមេរៀនទីពីរទេ? យើងរៀនអំពីពេលព្រះបានបង្កើតមនុស្ស។ ទ្រង់បង្កើតមនុស្សឲ្យមានលក្ខណខ្លះដូចជាព្រះអង្គ ដើម្បីទំនាក់ទំនងជាមួយព្រះ បម្រើព្រះ មើលថែផែនដីដែលព្រះអង្គបង្កើតមក ហើយធ្វើជាដំណាងព្រះ។ ប៉ុន្តែយើងបានធ្វើអ្វីទៅវិញ? យើងមិនស្គាល់ព្រះ ថ្វាយបង្គំព្រះដទៃផ្សេងទៀត ហើយកាន់សាសនាដែលមនុស្សបង្កើតមកវិញ យើងមិនថែរក្សារផែនដីទេ ផ្ទុយទៅវិញ នាំគ្រប់ទាំងអំពើបាបមកបង្ខូចផែនដីវិញ! យើងមិនមែនជាដំណាងព្រះដ៏ល្អទៀតទេ ឥឡូវយើងមើលទៅដូចជាតំណាងសម្រាប់អារក្សវិញ!

តែព្រោះគម្ពីរថា «**ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង**» សេចក្តីស្រលាញ់របស់ទ្រង់អស្ចារ្យ!

តើលោកអ្នកស្គាល់ក្រឹត្យវិន័យរបស់ព្រះដែលធំជាងគេទេ? មានពីរ

**ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «"ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ឲ្យអស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីគំនិតរបស់អ្នក" 38 នេះជាបទបញ្ញាទីមួយ ហើយសំខាន់ជាងគេ។ 39 ហើយបទបញ្ញាទីពីរក៏សំខាន់ដូចគ្នា គឺ "ត្រូវស្រឡាញ់អ្នកជិតខាងរបស់អ្នកដូចខ្លួនឯង"»។ ម៉ាថាយ ២២:៣៧-៣៩**

តើយើងស្រលាញ់ព្រះ អស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីគំនិត របស់ខ្លួនទេ? ទេ! យើងរមិលគុណព្រះវិញ។

តើយើងស្រលាញ់អ្នកជិតខាងដូចស្រលាញ់ខ្លួនឯងទេ! ទេ!

តែព្រោះគម្ពីរថា «**ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង**»

ទោះបើជាព្រះអង្គសម្រេចព្រះហឫទ័យឲ្យស្រលាញ់យើងក៏ដោយ ព្រះបរិសុទ្ធ និងយុត្តិធម៌ដែរ។ យើងសមតែស្លាប់ ធ្លាក់ស្ថាននរក និងទទួលវេទនារៀងរហូតតទៅ ពិព្រោះបាបរបស់យើង។ បាបមានទោសធ្ងន់ណាស!

ពីព្រោះព្រះស្រឡាញ់មនុស្សលោកជាខ្លាំងមែន ព្រះអង្គបានរៀបចំផ្លូវមួយដើម្បីសង្គ្រោះយើង លទ្ធផល យើងអាចជានានិងព្រះអង្គបាន។ មានផ្លូវសងថ្លៃលោះបាបរបស់យើង។

យើងនឹងសិក្សារពីផែនការរបស់ព្រះ ដើម្បីសង្គ្រោះយើងនូវមេរៀនក្រោយ។